ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០២ សហវ.ឧ.ក

ថ្ងៃព្រហស្បតិ៍ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០

# ប្រកាស
## ស្តីពី
## កម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំត្រីមាសទី ២ ឆ្នាំ ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- យោងតាមការចាំបាច់ដើម្បីរក្សាតុល្យភាពនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

# សម្រេច

**ប្រការ១ .-** ចំណូលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលខិតខំប្រមូលសម្រាប់ត្រីមាសទី ២ ឆ្នាំ ២០២០ សរុបទឹកប្រាក់ ចំនួន ២១ ៦២០ ១០០ ០០០ រៀល (ម្ភៃមួយប៊ីលានប្រាំមួយរយម្ភៃលានមួយរយពាន់រៀលគត់) ឬលើសកម្រិតកំណត់នេះ។ ចំណូលទាំងអស់នេះ ត្រូវបង់ចូលថវិកាថ្នាក់ជាតិឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ហើយត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២០ | កម្មវិធីចំណូលប្រចាំត្រីមាសទី ២ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមេសា | ខែឧសភា | ខែមិថុនា | |
| សរុបរួម | **77.233.500** | **21.620.100** | **7.206.702** | **7.206.699** | **7.206.699** | |
| ៧៣ | 77.093.500 | 21.592.539 | 7.197.515 | 7.197.512 | 7.197.512 | |
| ៧៤ | 140.000 | 27.561 | 9.187 | 9.187 | 9.187 | |

**ប្រការ២ .-** ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ចំណាយប្រចាំត្រីមាសទី ២ ឆ្នាំ ២០២០ ត្រូវបានកំណត់ស្មើនឹង ៣៩ ៩០០ ០០០ ០០០ រៀល (សាមសិបប្រាំបួនប៊ីលានប្រាំបួនរយលានរៀលគត់)។ ចំនួនទឹកប្រាក់នៃឥណទាននេះ ត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២០ | កម្មវិធីចំណាយប្រចាំត្រីមាសទី ២ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមេសា | ខែឧសភា | ខែមិថុនា | |
| សរុបរួម | **207.752.900** | **39.900.000** | **14.350.000** | **12.850.000** | **12.700.000** | |
| ៦០ | 33.926.000 | 5.400.000 | 1.800.000 | 1.800.000 | 1.800.000 | |
| ៦១ | 30.334.000 | 4.650.000 | 1.550.000 | 1.550.000 | 1.550.000 | |
| ៦៤ | 87.165.200 | 24.750.000 | 8.250.000 | 8.250.000 | 8.250.000 | |
| ៦២ | 36.882.900 | 2.850.000 | 2.000.000 | 500.000 | 350.000 | |
| ៦៥ | 19.384.800 | 2.250.000 | 750.000 | 750.000 | 750.000 | |
| ៦៣ | 60.000 | 0 | 0 | 0 | 0 | |

**ប្រការ៣ .-** អាណត្តិបើកប្រាក់ ដែលចេញដោយអាណាប័កដើមខ្សែលើសពីចំនួនទឹកប្រាក់កម្រិតកំណត់ខាងលើ និងលើសពីការបែងចែកតាមជំពូកនៃថវិកាខាងលើ មិនត្រូវបានទទួលការចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ហើយក៏មិនត្រូវបានធ្វើការបើកផ្តល់ដោយបេឡារតនាគារដែរ។

**ប្រការ៤ .-** រាល់ចំណាយចាំបាច់លើសពីកម្រិតកំណត់ឥណទានដូចមានចែងក្នុងប្រការ ២ ត្រូវមានការអនុញ្ញាតពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥ .-** អាណាប័កដើមខ្សែក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ